ទស្សនាវដ្ដី
សម្លេងខ្មែរនៅបរទេស

# ការដួលរលំរបស់សម្ដេចសីហនុ

## La chute du Prince Sihanouk

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១ មិថុនា ២០០៦

★★★ ពីថ្ងៃទី១១ មីនា ទៅទី១៨ មីនា (១៩៧០)... មានគម្លាតតែ១សប្ដាហ៍ប៉ុណ្ណោះ ។ ដូច្នេះប្រទេសកម្ពុជានៅសល់ពេលតែ៧ថ្ងៃ ដើម្បីរៀបចំធ្វើសង្គ្រាម !! គឺបានសេចក្ដីថា ឧត្ដមសេនីយ៍លន់-នល់ និងប្រជាជាតិខ្មែរ គ្រាន់តែជាអ្នករត់តាមព្រឹត្តិការណ៍ទាំងអស់គ្នា ។ ការដឹកនាំសាច់រឿងនៃ«រដ្ឋប្រហារថ្ងៃទី១៨ មីនា ១៩៧០» បានធ្វើឡើងពីខាងក្រៅទាំងស្រុង ៖ ដោយស្ដេចសីហនុ ហើយនិងពួកយួនឈ្លានពាន ។

❑

❑ ❑

នៅថ្ងៃទី១២ មីនា ១៩៧០, ខ្ញុំបានដឹងតាមរយៈអាកាប៉េ អំពីគោលជំហរជាផ្លូវការរបស់រាជរដ្ឋាភិបាល ដែលបានទទួលស្គាល់ដោយ«សេចក្ដីរំភើប» ថាមហាបាតុកម្មប្រជាប្រិយកាលពីថ្ងៃអាទិត្យកន្លងទៅ ជានិមិត្តរូបនៃ«ការភ្ញាក់រឭករបស់ជនជាតិខ្មែរទាំងមូល ចំពោះសភាពការណ៍ធ្ងន់ធ្ងរមិនធ្លាប់ដែលមាន និងគ្រោះថ្នាក់ដល់ស្លាប់ដែលកំពុងគំរាមកំហែងពួកគេក្នុងឋានៈជាប្រជាជាតិ»... ហើយរដ្ឋាភិបាលក៏បានធ្វើសេចក្ដីសន្យាថា នឹងធ្វើចំណាត់ការដោយគ្មានបង្អែរបង្អង់ និងដោយតឹងរ៉ឹងជាទីបំផុត ឲ្យពួក«ជនបរទេស» (ពួកយៀកកុង) គោរពខ្សែបន្ទាត់នយោបាយអព្យាក្រឹត្យ, ឯករាជ្យ និងបូរណភាពទឹកដីរបស់យើង ។ ទាំងនេះជាពាក្យឃ្លោងឃ្លាតគលំអតុបតែង របស់លោកមេទ័ពលន់-នល់ ដែលមានសភាវៈគោងទាមយ៉ាងគ្មានរបេះនឹងអព្យាក្រឹតភាពដ៏យល់សប្តិយល់សួងរបស់សម្ដេចឪជាអម្ចាស់ ។ នៅពេលជាមួយគ្នានោះ លោកនាយករដ្ឋាភិបាលដែលគេចាត់ទុកថា ជាមនុស្សខ្លាំងនៅចំពោះមុខសភាពការណ៍ភ្លុកក្រឡាប់... ក៏បានធ្វើសេចក្ដីអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរ សូមឲ្យមានអារម្មណ៍ស្ងប់ស្ងៀម ។ រឿងនេះមានលក្ខណៈសំខាន់ណាស់... ពីព្រោះលោកបានបង្ហាញដោយគ្មានលាក់លៀមថា លោកបានឈរនៅខាងពួកប្រជាបាតុករ ។

ខ្ញុំក៏បានដឹងផងដែរ ដោយមាត់មនុស្សនិយាយតគ្នា ថាបាតុកម្មប្រជាប្រិយរបស់យើង នៅល្ងាចថ្ងៃទី១១ មីនា ក៏បានប្រែក្លាយទៅជាទង្វើបះបោរហឹង្សារាលដាល

ទៅដល់សហាគមយួនសង្កាត់លេខ៦ និងជ្រោយចង្វា ។ ពាក្យចចាមអារាមបានផ្សាយរួចទៅហើយថា ពួកយៀកកុងបានដើរតាមក្រោយគន្លងដាននៃហ្វូងប្រជាពលកររបស់យើង ដោយពិឃាតពួកយួនអ្នកជាតិនិយម និងពួកកាតូលិក រួចហើយគ្រវែងរូបកាយពួកនេះទៅក្នុងទឹកទន្លេមេគង្គ ដើម្បីទម្លាក់ទោសកំហុសមកលើកងទ័ពរបស់យើង ។ ស្ទៀតបែបដូចនេះ ពួកវាធ្លាប់ប្រើរួចទៅហើយនៅវៀតណាមខាងត្បូង ។ ឃើញថាទង្វើហឹង្សានៅស្រុកយើងនេះ ក៏ពួកយៀកកុងចង់បានដូចគ្នាដែរ ដើម្បីបង្កើតសភាពច្របូកច្របល់នៅក្នុងប្រទេសរបស់យើង ។ បានសេចក្តីថា ពួកនេះបានប្រុងប្រៀបរៀបចំធ្វើសង្គ្រាមរួចស្រេចទៅហើយនៅប្រទេសកម្ពុជា ពោលគឺរៀបចំប្រឈមមុខចំពោះគ្រប់សភាពការណ៍ ។ នៅពេលដែលជនខ្មែរបានដុតបំផ្លាញផ្ទះសំបែង ដោយកំហឹងរំជើបរំជួល ពុះពោរ ជាពិសេសដោយសេចក្តីភ័យខ្លាចតក់ស្លុតនឹងវត្តមានរបស់យួន (paranoïa), ពួកកុម្មុយនិស្តយួនវិញ តែងតែធ្វើអ្វីៗដោយរិះគិតពិចារណា និងដោយការគន់គូរទុកជាមុន ។ ប៉ុន្តែស្ថានការណ៍បានវិលត្រឡប់មករកសភាពស្ងប់ស្ងៀមវិញទៅហើយ នៅថ្ងៃទី១២ មីនា ១៩៧០ ។ ជាការច្បាស់ណាស់ លោកឧត្តមសេនីយ៍លន់-នល់ បានក្តោបក្តាប់សភាពការណ៍ទូទៅយ៉ាងឆាប់រហ័សឡើងវិញ ថ្វីបើជនជាតិខ្មែរមិនទាន់បានស្ងប់អារម្មណ៍នៅឡើយក៏ដោយ

ទោះជាយ៉ាងណាក្តី ប្រទេសកម្ពុជាទាំងមូលកំពុងស្ថិតនៅក្នុងសេចក្តីស្ងប់ស្ងាត់, នៅក្រៅសង្គ្រាម, ហើយពួកយើងក៏ចិញ្ចឹមចិត្តនឹកសង្ឃឹមថា នឹងមានអនាគតមួយដ៏ល្អប្រសើរ... ដោយអាចគេចរួចពីគំនរទុក្ខ និងសេចក្តីឈឺចាប់នៃសឹកសង្គ្រាមដែលបានយាយីប្រទេសវៀតណាម ។ ខ្ញុំសូមទទួលស្គាល់ថា កាលសម័យនោះ គ្មាននរណាម្នាក់នឹកភ្នកដល់បញ្ហាចម្បាំងរាំងជល់នោះទេ ។ យើងមិនបាននឹកស្មាន សូម្បីប៉ុនសរសៃសក់ក៏គ្មានផង... ថាយើងនឹងអាចធ្លាក់ទៅជាចំណីនៃភ្លើងឆេះកល្បមួយ ដែលនឹងត្របាក់រូបកាយយើងទាំងអស់គ្នា ។ យើងបានដឹងជាក់ច្បាស់ណាស់អំពីសិទ្ធិត្រឹមត្រូវរបស់យើងជាខ្មែរម្ចាស់ប្រទេស តទល់នឹងពួកយៀកកុង ។ ម្យ៉ាងវិញទៀត ភ្លើងកំហឹងដ៏សន្ធោសន្ធៅប្រឆាំងយួននេះ ក៏វាបណ្តាលមកពីការភ័យខ្លាចសភាពការណ៍រឹតរួតថប់ដង្ហើម (រស់នៅកណ្តាលអគ្គីភ័យ) ដែលអាចរុញច្រានយើង ឲ្យរមៀលធ្លាក់ក្នុងភ្លើងសង្គ្រាម ទៅតាមគន្លងធម៌របស់ពួកយៀកកុងនេះឯង ។ ក៏ប៉ុន្តែពេលនោះ ក៏ស្រាប់តែផែនដីខ្មែរមានការរញ្ជួយយ៉ាងខ្លាំងតែម្តង ។ គឺជាសម្លេងបណ្តាសាររបស់ព្រះ ដែលលាន់ឡើងខ្ទរខ្ទារផែនដី... ខ្លាំងជាងសម្លេងរន្ទះបាញ់ទៅទៀត ។ មិនមែនជាសម្លេងយៀកកុងទេ ក៏ប៉ុន្តែក៏វាដូចតែគ្នា ។ គឺជាសម្លេងរបស់ព្រាយបិសាច, មេអារក្សសាតាំង, សម្លេងរបស់សម្តេចសីហនុដែលជា«អម្ចាស់របស់យើង»... សម្លេងនៃសេចក្តីអាម៉ាស់របស់ជាតិខ្មែរទាំងមូល ។ គឺជាវាសនាកម្មមួយ ដែលពិបាកទ្រាំទ្រពេកណាស់...

នៅថ្ងៃរសៀលទី១២មីនា, ខ្ញុំបានទទួលសន្លឹកឯកសារសម្ងាត់របស់អាកាប៉េ ប-

ង្ហាញពីសារទូលេខដែលសម្តេចសីហនុ បានផ្ញើទៅមាតារបស់ទ្រង់ ព្រះមហាក្សត្រី កុសុមៈ, នៅថ្ងៃដដែល ។ នៅពេលខ្ញុំអានអត្ថបទពិសេសនោះកាលណា ខ្ញុំមានអារម្មណ៍ថា ព្រះធរណីកំពុងស្រូបរូបខ្ញុំទាំងរស់តែម្តង ដោយសម្តេចសីហនុបានផ្តន្ទាទោសយ៉ាងតឹងរ៉ឹង ទៅលើពួកប្រជាបាតុករដែលទ្រង់ចោទថាជា «ពួកអ្នកស្នេហាជាតិស្រែកឃ្លានប្រាក់ដុល្លារ» ៖

«...ខ្ញុំមិនអាចជឿសោះថា ពួកគេអាចធ្លាក់ដល់សភាពចុងប៉ូចនិយមបែបដូចនេះសោះ ដែលវាផ្ទុយនឹងផលប្រយោជន៍ខ្ពង់ខ្ពស់ និងកេរ្តិ៍ឈ្មោះរបស់ប្រទេសយើង (sic!)... ខ្ញុំដឹងច្បាស់ណាស់ ថាព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរនេះ ត្រូវបានឥស្សរជនខ្លះរៀបចំឡើង ក្នុងគោលបំណងបំផ្លិចបំផ្លាញមិនឲ្យកែកុនបាន អំពីមិត្តភាពរវាងកម្ពុជានិងពិភពសង្គមនិយម ព្រមទាំងរុញច្រានប្រទេសយើងឲ្យធ្លាក់ចូលទៅក្នុងកណ្តាប់ដៃនៃអំណាចចក្រពត្តិនិយមនិងមូលធននិយម... (sic!) ។ ពួកទាំងនេះបានវាយតម្លៃផលប្រយោជន៍ផ្ទាល់ខ្លួននិងបក្សពួកគេ នៅពីលើអនាគតរបស់ប្រទេសជាតិ និងវាសនាប្រជាពលរដ្ឋ (sic!)...» ។ នៅក្នុងទូរលេខដដែលនេះ សម្តេចសីហនុបានបន្ថែម ដូចដែលទ្រង់ធ្លាប់បានពោលច្រើនដងកាលពីលើកមុនរួចហើយថាទ្រង់នឹងស្ម័គ្រចិត្តចាកចេញពីអំណាច តែមិនជ្រើសរើសយកផ្លូវដើររបស់ពួកឥស្សរជនខាងស្តាំទាំងនេះឡើយ ។ ទ្រង់បានថ្លែងបញ្ជាក់ថា គឺសុទ្ធសឹងជាពួក «វរជនស្នេហាប្រាក់ដុល្លារ», ថាពួកគេបានឆ្លៀតចំណេញយ៉ាងរបៀបកំសាកពីអវត្តមានរបស់ទ្រង់... ហើយថាទ្រង់នឹងត្រឡប់មកកាន់ប្រទេសជាតិវិញ ដើម្បីនិយាយទៅកាន់ប្រជាពលរដ្ឋ...

បន្ទាប់ពីបានពោលវាចាប្រកបដោយពិសពុលនេះ, វាចាដែលពោរពេញដោយពុតត្បុតនិងល្បិចកល, វាចាបោកប្រាស់យ៉ាងសាហាវឃោរឃៅសមសក្តិនឹងមេធ្មប់ម៉ាគ្គីយ៉ាវែល, ផ្ទៃមេឃដ៏សុខសាន្តត្រាណនៃកម្ពុជា ក៏ត្រូវរហែករហុយរបើករបាញដោយពុំមានពេលវិលត្រឡប់ ។

❑

❑ ❑

ពាក្យចចាមអារាមដែលហាមឃាត់មិនបាន កំពុងតែរាលដាលដូចភ្លើងឆាបឆេះប្រេងសាំង ហើយដែលនិយាយថាសម្តេចសីហនុ នឹងយាងត្រឡប់មកវិញក្នុងពេលឆាប់ៗចូលមកប្រទេសកម្ពុជា, ថាយន្តហោះទ្រង់នឹងចុះនៅក្នុងពេលពីរបីថ្ងៃទៀត ប៉ុណ្ណោះនៅសៀមរាប ពុំមែននៅភ្នំពេញទេ, ប្រហែលជានៅក្នុងថ្ងៃអាទិត្យខាងមុខក៏មិនដឹង, ហើយថានឹងមានការបញ្ជូនទាហានមួយកង ដើម្បីទៅបាញ់ប្រហារព្រះអង្គ នៅពេលដែលទ្រង់ចុះពីលើយន្តហោះ ។ សេចក្តីតក់ស្លុតរបស់ខ្ញុំក៏កើនទំហំមួយជាពីរ ។ បើទោះជាខ្ញុំបន់ស្រន់ឲ្យពាក្យចចាមអារាមនេះ ក្លាយទៅជាការពិតយ៉ាងណាក្តី យ៉ាងហោចណាស់ក៏សំរាប់ការពារស្បែកខ្លួនឯង... ក៏ប៉ុន្តែខ្ញុំមិនអាចមាន

ជំនឿទៅលើពាក្យរសាត់តាមខ្យល់ទាំងនេះទេ ។ តើកងទាហាននេះនៅឯណាទៅ ? ជាដាច់ខាត (ប្រសិនបើមានកងទាហានទាំងនេះពិតមែន) ពួកច្បាស់ជាមិនហ៊ានលើកដៃតម្រង់ទៅលើព្រះប្រមុខរដ្ឋសោះឡើយ ។ ដើម្បីបំពេញរដ្ឋប្រហារនៅពេលនោះ គេត្រូវមានលក្ខន្តិកៈពីរយ៉ាងដោយចៀសមិនរួច គឺកត្តាចាំបាច់ហើយនិងកត្តាគ្រប់គ្រាន់ (La condition nécessaire et la condition suffisante) ៖ គេត្រូវមានគំរោងផែនការ ហើយត្រូវមានឆន្ទៈប្ដូរផ្ដាច់ដើម្បីសំរេចគំរោងនោះ ។ លោកលន់-នល់គាត់គ្មានទាំងពីរ គំរោងក៏គ្មាន ឆន្ទៈក៏គ្មាន ។ ចំណង់ ឬគំនិតទម្លាក់ស្ដេចសីហនុមិនដែលបានរសាត់មកក្បែររូបគាត់ទេ ។ បើមេមិនហ៊ានយ៉ាងដូច្នេះទៅហើយ តើមានកូនឯណាហ៊ានធ្វើជំនួសមេ ?

ដូច្នេះ (រឿងទម្លាក់សីហនុ) មិនមែនជារដ្ឋប្រហារទេ ។ យ៉ាងច្រើនណាស់ គេអាចប្រៀបធៀបទៅនឹងរឿងបះបោរនៅក្នុងនាវា, ដូចរឿងអាមេរិកាំង The Caine Muting ។ នាវាកម្ពុជាកំពុងតែស្ថិតនៅកណ្ដាលខ្យល់ព្យុះ ហើយរកកលក្រឡាប់ទៅលើថ្មស្រួច ។ ពួកកងនាវាទាំងអស់ស្រាប់តែក្រឡេកឃើញថា នាវាកំពុងរៀបចំលិចហើយ ។ លន់-នល់ជនទី២ដែលនៅជាប់នឹងចង្កូត ខំប្រឹងប្រែងជួយសង្គ្រោះនាវាអស់ពីសមត្ថភាព ដោយកាច់ចង្កូចទៅខាងស្ដាំ, ចំណែកស្ដេចសីហនុមេបញ្ជាការនាវា ដែលចំពេលនោះកំពុងធ្លាក់ចូលក្នុងវិកលចរិត ក៏ស្រែកបញ្ជាផ្ទុយទៅវិញ (ឲ្យកាច់ចង្កូចទៅខាងកុម្មុយនិស្ដ) ។ កងនាវាទាំងអស់ ពោលឲ្យខ្លីទៅគឺក្រុមរាជការសង្គរាស្ត្រនិយមទាំងមូល មានរដ្ឋមន្ត្រី អ្នកតំណាងរាស្ត្រ មេទាហាន ចៅហ្វាយខេត្តខណ្ឌ ក៏បែរមកស្ដាប់បង្គាប់បញ្ជាលន់-នល់ ដែលគេចាត់ទុកថា ជាមេដឹកនាំសំរាប់ស្រោចស្រង់ជាតិ ។ ពួកគេលែងខ្វល់ខ្វាយនឹងស្ដេចសីហនុមួយរយៈពេល ពីព្រោះពួកគេត្រូវការគិតទៅដល់អាយុជីវិតរបស់ខ្លួនឯងជាមុនសិន ។ ទោះជាយ៉ាងណាក្ដីព្រះប្រមុខរដ្ឋឬតួអង្គស្ដេចឆ្កួតពុំបានស្ថិតនៅក្នុងស្រុកទេ... ព្រះអង្គបានសំរេចចាកចេញដោយខ្លួនឯងនៅកណ្ដាលខ្យល់ព្យុះ ។ តើនៅត្រង់កន្លែងណា ដែលថាលន់-នល់មានគំនិតក្បត់ចង់ដណ្ដើមអំណាចនោះ ??

ម៉្យាងវិញទៀតលោកនាយករដ្ឋាភិបាលកំពុងតែត្រូវ«ងាប់ក្រឡា», ពោលក្លាយទៅជាជនពិការនយោបាយ ដោយសារតែសេចក្ដីថ្កោលទោសរបស់ព្រះប្រមុខរដ្ឋ ។ លោកលន់-នល់លែងអាចធ្វើអ្វីទៀតបាន ក្រៅពីការរត់ប្រាយទៅមុខថែមទៀត ។ នៅក្នុងរបាយការណ៍មួយដ៏គួរឲ្យរំភើប ដែលលោកសរសេរខ្លួនឯង ហើយវាយជាសារទូរលេខបញ្ជូនទៅព្រះអគ្គមគ្គុទ្ទេសក៍ លោកបានស្នើសុំបន្ថែមទ័ពពី៣៥,០០០ទៅ៤៥,០០០នាក់ (គឺបន្ថែម១០,០០០នាក់) ។ លោកបានប្រឹងប្រែងអង្វរករព្រះប្រមុខរដ្ឋ ឲ្យលើកលែងទោសដល់ពួកប្រជាបាតុករ និងក្រុមរាជការដែលដឹកនាំបាតុកម្មដោយបញ្ជាក់ថា ៖ «ព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរនេះ គឺជាលទ្ធផលនៃការផ្ទុះកំហឹងរបស់ប្រជាពលរដ្ឋមួយ ដែលបានទទួលសេចក្ដីឈឺចាប់រាប់ឆ្នាំមកហើយៗដែលកំពុងចា

ប់អារម្មណ៍ទៅលើគ្រោះថ្នាក់ ដែលកំពុងគំរាមកំហែងទៅលើប្រទេសរបស់ខ្លួន» ។ ដើម្បីល្បួងលោមសម្តេចសីហនុឲ្យត្រជាក់ចិត្ត លោកលន់-នល់បានបន្ថែមទៀតថា

«★ រាជរដ្ឋាភិបាលនឹងខំស្វែងរកដំណោះស្រាយមួយដ៏ត្រឹមត្រូវ ស្របច្បាប់ ហើយសមស្របជាមួយឧត្តមគតិប្រជាពលរដ្ឋ» ។

«★ រាជរដ្ឋាភិបាលយល់ថា មានតែមធ្យោបាយសមស្របជាមួយនឹងឧត្តមគតិប្រជាពលរដ្ឋនោះទេ ដែលអាចស្រោចស្រង់ប្រទេសជាតិយើង ឲ្យឆ្លងរួចផុតពីគ្រោះអាសន្ន ។

«★ ឥតមានន័យអ្វីដែលរាជរដ្ឋាភិបាលត្រូវទៅចូលបក្សសេអាតូ ឬទៅចូលបក្សផ្សេងទៀតនោះទេ, នយោបាយអ្វីក៏ដោយដែលរណបគេ គឺផ្ទុយនឹងនយោបាយជាតិដែលត្រួសត្រាយដោយសម្តេចឪ

«★ ដោយមិនភ្លេចពីនយោបាយមានទៅមានមករបស់យើង រាជរដ្ឋាភិបាលមានយោបល់ថា ត្រូវតែថែរក្សាមិត្តភាពជាមួយនឹងពួកយៀកកុង» ។

ពីទីក្រុងប៉ារីស, នៅថ្ងៃដដែល សម្តេចសីហនុបានឆ្លើយតបដោយមិនចំពោះទៅលោកលន់-នល់ថា ដរាបណាទ្រង់នៅកាន់អំណាច ទ្រង់មិនអនុញ្ញាតដាច់ខាតឲ្យមានការបង្កើនកងទ័ពខ្មែរ ពីព្រោះវាគ្មានបានប្រយោជន៍អ្វីទេ គឺដោយហេតុថា កងទ័ពអាមេរិកាំង-វៀតណាមខាងត្បូងមានចំនួនច្រើនលើសលប់ យ៉ាងណាក៏មិនអាចឈ្នះពួកកងកម្លាំងតស៊ូយៀកកុងបានដែរ ។ នេះជាសេចក្តីថ្លែងការណ៍របស់ Gribouille (ជនម្នាក់ដែលខ្លាចភ្លៀងទទឹក ក៏លោតចូលទៅក្នុងស្ទឹងបណ្តោយ) ព្រមទាំងជានិមិត្តរូបនៃសេចក្តីអាម៉ាស់របស់ជនជាតិខ្មែរយើង ។ ដោយមានឫកក្រអឺតក្រទមខ្លាំងណាស់, ស្តេចសីហនុបានយល់ឃើញថា និយាយគ្នាទាក់ទងផ្ទាល់ជាមួយនឹងរដ្ឋមន្ត្រីទី១របស់ទ្រង់ គឺជាការដែលមិនសមសក្តិនឹងទ្រង់ ។ ម្ល៉ោះហើយទំនាក់ទំនងគ្នា រវាងព្រះអង្គនិងលោកលន់-នល់, មនុស្សតែម្នាក់ដែលនៅក្នុងកាល:ទេស:នោះ អាចផ្តល់អំណាចទេវរាជមកដល់ព្រះអង្គវិញ ក៏ត្រូវដាច់គ្នាត្រឹមនោះឯង ។ ចំណែកខ្លួនខ្ញុំវិញ ខ្ញុំនឹកក្នុងចិត្តថា ៖ «គាត់នេះមិនព្រមបង្កើនកងទ័ពខ្លួនឯងទេ ពីព្រោះគាត់លក់ខ្លួនឲ្យយួនរួចទៅហើយ... នេះហើយជាភស្តុតាងជាក់ស្តែង» ។

❑

❑ ❑

នៅថ្ងៃទី១៣ មីនា ១៩៧០, ខ្ញុំបានបោះផ្សាយអត្ថបទវិចារណកថាមួយ ដែលប្រឆាំងយ៉ាងខ្លាំងនឹងនយោបាយរបស់សម្តេចសីហនុ (ប្រសិនបើជាមានរដ្ឋប្រហារពិតមែន គឺខ្ញុំនេះហើយជាអ្នកធ្វើរដ្ឋប្រហារតែម្នាក់ឯង) ។ ខ្ញុំបានសំរេចចិត្តថា មិនស្វែងទៅរកជំរកគាំពារនៅផ្ទះរបស់លោកលន់-នល់ ឬរបស់ទ្រង់សិរិមត:នោះទេ ។ ពួកគាត់ក៏ដូចតែរូបខ្ញុំដែរ គឺជាពួកអ្នកនយោបាយដើរចូលក្នុងផ្លូវទ័ល ។ ម្ល៉ោះក៏ដូចជាការរត់ប្រាស់អាយុទាំងអស់គ្នា ម្នាក់ៗគឺសំដៅយករួចខ្លួនៗឯងជាមុន ។ ខ្ញុំបានសំរេ

ចចិត្ត មិនរង់ចាំយោបល់ពួកគាត់ទៀតទេ មុននឹងបោះជំហាននយោបាយធំៗ... ពេលខ្ញុំបានសំរេចចិត្តក្លាយទៅជាជនបះបោរ ដោយរត់ទៅមុនរដ្ឋាភិបាល ក្នុងការតស៊ូប្រឆាំងនឹងនយោបាយក្បត់ជាតិនិងប្រួកុម្មុយនិស្តរបស់ព្រះប្រមុខរដ្ឋ ។ ខ្ញុំបានដាក់ចំណងជើងនៃអត្ថបទរបស់ខ្ញុំថា ៖ «យើងបានមកដល់ផ្លូវបែក» ។ ខ្ញុំបានបង្ហាញដល់មិត្តអ្នកអានរបស់ខ្ញុំថា ៖ «នៅក្នុងសន្ទុះនៃសេចក្ដីស្នេហាជាតិ ពួកជនជាតិខ្មែរបានងើបឡើងធ្វើបាតុកម្ម ដើម្បីសំដែងនូវឆន្ទៈរបស់ពួកគេ បណ្ដេញពួកយៀកកុងចេញពីទឹកដីរបស់យើង ។ ជនណាក៏ដោយដែលហ៊ានប្រឆាំងនឹងឆន្ទៈប្រជាពលរដ្ឋនេះ គឺកំពុងតែតាំងខ្លួននៅក្រៅសង្គមជាតិ... ម៉្លោះហើយគឺតាំងខ្លួននៅខាងជួររបស់ខ្មាំងសត្រូវ ។ ជនណាដែលធ្វើរបងការពារឲ្យពួកយៀកកុង, ពួកអ្នកយកជើងរាទឹក បើទោះជាកាន់តំណែងខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ គឺបានសេចក្ដីថា ពួកគេតំណាងផលប្រយោជន៍របស់យៀកកុងតែប៉ុណ្ណោះ ។ ផ្លូវរបស់គេដើរ កំពុងតែបែកចេញពីផ្លូវរបស់យើងរួចហើយ ។ យើងជាជនជាតិខ្មែរមានករណិយកិច្ចត្រូវឃាត់ឃាំងដាច់ខាតពួកជនទាំងនេះ កុំឲ្យបំផ្លិចបំផ្លាញសង្គមជាតិរបស់យើង !» ។

នៅព្រឹកថ្ងៃទី១៤ មីនា ១៩៧០, លោកស៊ឹម-វ៉ារ ឪពុកធំរបស់ខ្ញុំបានកោះហៅខ្ញុំទៅជួបគាត់ ។ ខ្ញុំក៏បានទៅជួបគាត់ប្រហែលជាម៉ោង៩ព្រឹក ។ ខ្ញុំកំពុងរង់ចាំថា គាត់នឹងស្ដីបន្ទោសដល់រូបខ្ញុំជាមិនខាន... ពីព្រោះក្នុងប៉ុន្មានថ្ងៃចុងក្រោយនេះ ខ្ញុំបានទៅឆ្ងាយហួសពេក ដោយមិនរវីរវល់នឹងយោបល់របស់គាត់ ។ ប៉ុន្តែឪពុកធំរបស់ខ្ញុំបាននិយាយមកកាន់រូបខ្ញុំដោយសម្លេងទន់ភ្លន់ថា គាត់គាំទ្រអត្ថបទចុងក្រោយរបស់ខ្ញុំ ៖ «យើងដើរមកដល់ផ្លូវបែក»...។ ក្នុងពេលជាមួយគ្នានោះ តាមរយៈឪពុកធំរបស់ខ្ញុំ ខ្ញុំក៏បានដឹងដោយធូរចិត្តថា អ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមតៈក៏គាំទ្រអត្ថបទរបស់ខ្ញុំផងដែរ ។ នៅពេលនោះខ្ញុំសប្បាយចិត្តណាស់ដោយដឹងថា រដ្ឋាភិបាលប្រកាន់ជំហរនៅខាងខ្ញុំ ។

- កាលពី week-end មុននេះ អ៊ំហើយនិងយ៉ូកូ (ប្រពន្ធរបស់គាត់) បានទៅសំរាកនៅសៀមរាប ។ អ៊ំមិនបានដឹងអំពីព្រឹត្តិការណ៍អស់ទាំងនេះទេ...

ដូច្នេះលោកស៊ឹម-វ៉ារ ដែលគេបានចោទថា ជាខួរក្បាលនៃពួកជនក្បត់ប្រឆាំងនឹងស្ដេចសីហនុ... គាត់បានដឹងអំពីបាតុកម្មប្រឆាំងយួន នៅពេលដែលព្រឹត្តិការណ៍នេះកើតឡើងរួចហើយតែប៉ុណ្ណោះ ។

ពេលនោះខ្ញុំឆ្លៀតសួរគាត់យ៉ាងរហ័ស ៖

- លោកអ៊ំបានទៅជួបព្រះមហាក្សត្រីយានីឬទេ ?

- ទេ... តើទៅជួបបានការអ្វី ? ម្ដាយធ្វើម្ដេចនឹងចោលកូនបាន ! (លោកស៊ឹម-វ៉ារនិយាយទាំងអស់សង្ឃឹម) ។

❑

❑ ❑

នៅក្នុងសៀវភៅ «Cambodge, du sourire à l'horreur», លោក Jean Morice បានសរសេរអំពីពីថ្ងៃទី១៨ មីនា ១៩៧០ ដោយសេចក្តីដូច្នេះថា ៖

«នៅថ្ងៃទី១៨ មីនា ១៩៧០, ព្រះអង្គម្ចាស់កន្តុល ហើយនិងលោកយ៉ែម-សំបូរ បានទៅគេហស្ថានរបស់លោកលន់-នល់នៅទំនប់ទឹក ដើម្បីទទួលបញ្ជាចុងក្រោយពីលោក មុននឹងធ្វើដំណើរចាកចេញទៅ (ជួបស្តេចសីហនុ) ។ នៅពេលនោះអ្នកទាំងពីរក៏បានដឹងថា សីហនុត្រូវធ្វើដំណើរចាកចេញពីទីក្រុងប៉ារីស ឆ្ពោះទៅក្រុងម៉ូស្គូ នៅថ្ងៃស្អែកឡើង គឺថ្ងៃទី១៥មីនា ។ ម្ល៉ោះហើយគេក៏រៀបចំជាប្រញាប់ធ្វើលិខិតឆ្លងដែន សំរាប់បេសកជនទាំងពីរ ទៅសហភាពសូវៀត ។ នៅប្រមាណជាម៉ោង ១១យប់ទៅហើយ, ទ្រង់កន្តុលហើយនិងលោកប្រធាន (ប្រតិភូ ?) យ៉ែម-សំបូរបានលាលោកលន់-នល់ និងក្រុមរដ្ឋមន្ត្រី និងនាយទាហានជាន់ខ្ពស់៤-៥នាក់ ដែលបានចូលរួមប្រជុំក្នុងកិច្ចសន្ទនា ។ ប៉ុន្តែនៅពេលដែលអ្នកទាំងពីរបានចាកចេញពីផ្ទះលន់-នល់បាន៨-១០ម៉ែត្រប៉ុណ្ណោះ... ស្រាប់តែគេឃើញលោកឧត្តមសេនីយ៍បោយដៃហៅឲ្យត្រឡប់មកវិញ ដោយលើកបង្ហាញអំពីទូរលេខមួយរបស់ស្តេចសីហនុ ដែលមានសេចក្តីដូចតទៅនេះ ៖

«ចូរប្រាប់កន្តុលហើយនិងយ៉ែម-សំបូរ ឲ្យត្រឡប់ទៅកម្ពុជាវិញទៅ (stop) ។ ខ្ញុំមិនត្រូវការជួបពួកទាំងនេះទេ (stop)» ។ (Cambodge, du sourire à l'horreur. page-196) ។

❑

❑ ❑

រសៀលនៃថ្ងៃ១៦ មីនា ១៩៧០ ។ ខ្ញុំមានអារម្មណ៍ថា ការបែកបាក់រវាងរដ្ឋាភិបាលហើយនិងសម្តេចសីហនុ ជាការដែលជៀសមិនរួច ។ លោកឧត្តមសេនីយ៍លន់-នល់បានចាត់ចែងឲ្យមានបាតុកម្មមួយដ៏ធំសំបើម ដើម្បីគាំទ្រគោលជំហររបស់រដ្ឋាភិបាល នៅចំពោះមុខរដ្ឋសភាជាតិ ។ នៅពេលនោះ គឺជាលើកទី១ហើយ ដែលលោកអ៊ុម-ម៉ាណូរិន, បងថ្លៃរបស់ព្រះប្រមុខរដ្ឋ, ធ្វើសកម្មភាពប្រឆាំងនឹងលោកលន់-នល់ ដោយបង្កើតបាតុកម្មជល់ជាមួយបាតុកម្ម ។ ក្រុមប៉ូលិសរបស់អ៊ុម-ម៉ាណូរិន ស្លៀកពាក់បន្លំជាស៊ីវិល ហើយដែលដឹកនាំដោយលេខាធិការផ្ទាល់របស់គាត់, លោកសក្តិបី អ៊ុក-ស៊ន បានចូលឡាយឡំជាមួយនឹងក្រុមបាតុករ ហើយក៏បានវាយតប់សាស្ត្រាចារ្យម្នាក់ ដែលជាអ្នកនាំពាក្យរបស់រដ្ឋាភិបាល ដោយចោទថាជាជនឃុបឃិត្បត់និងសម្តេចសីហនុ ។ លោកសាស្ត្រាចារ្យម្នាក់នេះ លើប៉ាណូមួយយ៉ាងធំ ដែលថ្កោលទោសអំពីនយោបាយពុករលួយនិងប្រកាន់បក្សពួក នៃពួកអ្នកកាន់តំណែងជាន់ខ្ពស់នៅក្នុងរដ្ឋ ដែលនៅក្នុងនោះមានអ៊ុម-ម៉ាណូរិនម្នាក់ដែរ ។ ការវាយប្រហារទៅលើមនុស្សតែម្នាក់នេះ ក៏បានក្លាយទៅជាការវាយប្រតប់គ្នាប៉ាតណាប៉ាតណី រវាងហ្វូងមនុស្សនិងហ្វូងមនុស្ស ។ ពួកខាងរដ្ឋាភិបាលដោយមិនបានប្រុងប្រៀបជាមុ

ន ក៏ចាប់ផ្ដើមមានការភ័យស្លន់ ។ ពួកឃាតកររបស់អ៊ុម-ម៉ាណូរិន គាំទ្រដោយកម្លាំងរបស់សុស្ដែន-ហ្វៀរណង់ដែស ក៏បានវាយពួករដ្ឋាភិបាលឡើងទ្រមខ្លួន ។ អន្ដរាគមន៍របស់អ៊ុម-ម៉ាណូរិន ក៏ជំរុញឲ្យមានព្រឹត្តិការណ៍មួយដ៏ជៀសមិនផុត ៖ គឺស-ង្គ្រាមនៃបដិវត្តន៍ផ្ទៃវាំង ។ ទង្វើហឹង្សារបស់អ៊ុម-ម៉ាណូរិន ក៏បង្កើតឲ្យមានប្រតិកម្មហឹង្សារបស់ឧត្ដមសេនីយ៍លន់-នល់ ជាពិសេសរបស់ទ្រង់សិរិមតៈ ៖ គឺការទម្លាក់ស្ដេចសីហនុជាបន្ទាន់ ។

តាមការពិត គោលបំណងអ៊ុម-ម៉ាណូរិនមិនបានចង់ការពារថៅហ្វាយរបស់ខ្លួនឯងនោះទេ (សម្ដេចសីហនុ), ប៉ុន្តែចង់ការពារខ្សែរយៈក្រុមអ្នករត់ពន្ធរបស់ខ្លួន ។ ខ្លួនគាត់ក៏ជាមនុស្សទ័លច្រកដែរ ម្ល៉ោះហើយទង្វើរបស់គាត់ មានគោលបំណងកំ-ហែងរដ្ឋសភាជាតិ ដែលនៅពេលនោះកំពុងធ្វើការប្រជុំពេញអង្គ ដើម្បីកាត់ទោសរូបគាត់ ។ ទទួលចំពេលនោះតែម្ដង អ្នកតំណាងរាស្ត្រស៊ឹម-វ៉ារកំពុងស្ដីបន្ទោសទៅលើរដ្ឋមន្ត្រីសន្តិសុខជាតិ សុស្ដែន-ហ្វៀរណង់ដែស ដែលត្រូវជាប់ចោទពីបទឃុបឃិត ជាមួយអ៊ុម-ម៉ាណូរិន ក្នុងប្រការរត់ពន្ធក្រណាត់មកពីទីក្រុងហុងកុង ។ សុ-ស្ដែនបានឡើងធ្វើសេចក្ដីថ្លែងការណ៍ប្រឆាំងយ៉ាងខែងរែង តទល់នឹងវាគ្មិនទាំងឡាយនៅរដ្ឋសភា... ហើយក៏បានបង្ហាញដល់សាធារណជនថា រឿងរត់ពន្ធនេះជារឿងចោទប្រកាន់ប្រហោងក្លួង ដែលឥតមានភស្ដុតាង ។ នៅក្នុងបរិយាកាសដ៏ច្របូកច្របល់អស្ចារ្យនេះ, អ្នកតំណាងរាស្ត្រ ដាញ់-សាង ដែលជាមនុស្សម្នាក់របស់ទ្រង់ស៊ីសុវត្ថិ-សិរិមតៈ ហើយដែលនៅក្នុងពេលថ្មីៗនេះ បានធ្វើការចោទប្រកាន់យ៉ាងខ្លាំងក្លា ទៅលើវត្តមានយៀកកុងនៅក្នុងទឹកដីខ្មែរ ក៏ស្រាប់តែប្ដូរទិសនយោបាយឡើងវិញស្រឡះ ។ លោកដាញ់-សាងប្រហែលជាមានការភ័យខ្លាចនឹងអ៊ុម-ម៉ាណូរិនហើយ ក៏លែងមានជំនឿទុកចិត្តលើរដ្ឋាភិបាល ។ ដោយឡើងទៅកាន់វេទិកាសភា, ដាញ់-សាងបានថ្លែងថា ៖ «...យើងធ្វើអ្វីៗត្រូវប្រយ័ត្នប្រយែង... កុំឲ្យប៉ះពាល់ដល់នយោបាយជាន់ខ្ពស់ដ៏ភ្លឺស្វាងរបស់សម្ដេចឪជាអម្ចាស់»...

❑

❑ ❑

ថ្ងៃទី១៧ មីនា ១៩៧០, ព្រះមហាក្សត្រីយានីកុសុមៈខំប្រឹងជួយសង្គ្រោះកូនរបស់ទ្រង់ជាចុងក្រោយ បើទោះជាស្ដេចកូនមិនចង់ឲ្យនរណាសង្គ្រោះយ៉ាងណាក្ដី ។ ដើម្បីបន្សាបកំហឹងប្រជារាស្ត្រ ទ្រង់បានធ្វើសេចក្ដីថ្លែងការណ៍មួយទៅកាន់ប្រជាជាតិ ដោយប្រកាន់នូវគោលជំហរគាំទ្រមហាបាតុកម្មប្រឆាំងនឹងយៀកកុង «ដែលអនុញ្ញាតឲ្យខ្ញុំមើលឃើញយ៉ាងជាក់ច្បាស់ នូវសេចក្ដីស្រឡាញ់ឥតប្រែប្រួល និងសេចក្ដីដឹងគុណដ៏ជ្រាលជ្រៅរបស់កូនចៅទាំងអស់គ្នា ចំពោះរូបខ្ញុំ ដែលកូនចៅចាត់ទុកថាជាព្រះមាតាជាតិ, ចំពោះប្រទេសជាតិមាតុភូមិ និងចំពោះសម្ដេចឧបយុវរាជព្រះប្រមុខរដ្ឋ» ។

ដូច្នេះព្រះមហាក្សត្រីយានីកុសុមៈដឹងច្បាស់ណាស់ថា មេដឹកនាំនៅពេលនោះអាចនិយាយគ្នាស្តាប់បាន (ពោលគឺអាចដើរចុះពីតំណែង) ។ លោកលន់-នល់ក៏ជាមនុស្សរបស់សីហនុ... ចំណែកទ្រង់សិរិមតៈក៏ជាក្មួយសំណាប់របស់ព្រះមហាក្សត្រីយានី ។ ការត្រូវប្រឈមមុខនឹងសង្គ្រាមស៊ីវិល គឺជារឿងមួយដ៏គួរឲ្យព្រឺរអារខ្លាំងណាស់ សំរាប់ប្រជាជាតិខ្មែរ, ហើយក្នុងប្រការនេះ មានតែស្តេចកូនមួយអង្គប៉ុណ្ណោះ ដែលគ្មាននរណានិយាយស្តាប់បាន ហើយគ្មាននរណាអាចទៅជួបបាន ។ នរោត្តម-សីហនុ ដោយសារទង្វើរឹងក្បាល មិនព្រមទាក់ទងគ្នា (សូម្បីជាមួយតំណាងព្រះមហាក្សត្រីយានី ដូចទ្រង់កន្តុល ក៏សីហនុមិនចង់ជួបដែរ)... គឺព្រះអង្គមានគោលប្រាថ្នាចង់ធ្វើសង្គ្រាមជាមួយកូនចៅរបស់ខ្លួនឯង ។ ដើម្បីការពារអ្នកម្នាងម៉ូនិកភរិយារបស់ទ្រង់ ហើយនិងពួកឃុនកុម្មុយនិស្ត ដែលអ្នកម្នាងជាអ្នកគាំពារពីធម្មជាតិ, ដើម្បីផ្តន្ទាពួកជនដែលបាត់បង់ជំនឿលើព្រះអង្គ, ទ្រង់ក៏បានរុញច្រានស្រុកទេសរបស់ខ្លួនឯង ទៅដល់មាត់ច្រកនៃសង្គ្រាម ។ អ្នកដែលមានបច្ចេកទេសខ្ពង់ខ្ពស់ខាងធ្វើអង្ករឲ្យក្លាយទៅជាបាយ រួចទើបស្រែកជាក្រោយនោះ (Le maître du fait accompli) គឺរូបព្រះអង្គឯង ! ។ ទ្រង់បានផ្ញើសារទូរលេខមួយច្បាប់ហើយមួយច្បាប់ទៀត ទៅមាតាព្រះអង្គ... គឺដើម្បីឲ្យទ្រង់ខូចកេរ្តិ៍ឈ្មោះ មិនមែនដើម្បីគាំទ្រទ្រង់នោះទេ ។ ហើយនៅពេលដែលមហាក្សត្រីយានីហើយនិងរាជរដ្ឋាភិបាលចង់បញ្ជូនមនុស្សពីរនាក់ឲ្យមកជួបព្រះអង្គ ស្តេចសីហនុស្រាប់តែមានអាកប្បកិរិយាដូចកូនក្មេងទំយើ ដូចស្តេចពាល ដោយព្រះអង្គឡាំប៉ាមិនចង់ដឹងមិនចង់ឮពីអ្វីទាំងអស់ ។ ក្នុងករណីនេះ ស្តេចសីហនុហាក់ដូចជារត់គេចពីម្តាយ និងពីរាជរដ្ឋាភិបាលរបស់ខ្លួន, ហាក់ដូចជាចោរហនេយ្យំ (សូមអានហាន់តាយ៉ុង) ម្នាក់ដែលមានវិប្បដិសារីញ៉ាំញី ហើយដែលភ័យខ្លាចគេដេញតាមទាន់ ។ ទ្រង់ខំប្រឹងរត់ប្រាយទៅទីក្រុងម៉ូស្គូ នៅក្នុងកិច្ចធ្វើដំណើរមួយដែលគ្មានលក្ខណៈអ្វីជាប្រញាប់សោះ ។ នេះគឺបានសេចក្តីថា ការសំរេចនយោបាយរបស់ព្រះអង្គ បានធ្វើរួចទៅហើយ ឥតត្រឡប់ថយក្រោយវិញទេ ។ ដោយធាក់ចោលជនអាជ្ញាកណ្តាល មានយ៉ែម-សំបូរហើយនិងនរោត្តម-កន្តុល, សម្តេចសីហនុដែលចុះមកពីពូជទេវរាជនៃទីក្រុងអង្គរ ក៏បានផ្តាច់ខ្លួនយ៉ាងស្អាតស្រឡះផេងពីប្រទេសជាតិរបស់ខ្លួនឯង ។ នេះគឺពីព្រោះថា ទ្រង់មានគោលប្រាថ្នាចង់ឲ្យគេទម្លាក់ ។ គឺដោយព្រោះព្រះអង្គចង់ផ្តួលព្រលំខ្លួនឯង ហើយក្នុងប្រការដកថយខ្លួនដោយខ្លួនឯង ចេញពីឆាកនយោបាយជាតិនេះ ទ្រង់មានគោលបំណងឲ្យទំនាស់វិវាទនៅក្នុងសង្គមជាតិរបស់ទ្រង់ មានដំណើរទៅមុខ.. ដើម្បីឲ្យសមស្របជាមួយនឹងទ្រឹស្តីចោទប្រកាន់របស់ទ្រង់ដែលថា មានរដ្ឋប្រហារនៅទីក្រុងភ្នំពេញ ហើយដែលទ្រង់បានរៀបចំតុបតែងឆ្នៃប្រឌិតតាំងពីដើមដល់ចប់តាមលំនាំសោកនាដកម្មរបស់ Shakespeare ។ ដូច្នេះរដ្ឋប្រហារដែលឥតមានសោះ ទ្រង់ក៏បង្កើតឲ្យមានដោយស្នាដៃរបស់ទ្រង់ជាមេធ្មប់ ។ ក៏ដូចតែរឿងភាពយន្តចុង

ក្រោយរបស់ទ្រង់ «សន្និប្រកាស» (អស្តង្គត) ដែលរៀបរាប់អំពិទង្វើក្បត់នៅក្នុងព្រះរាជវាំង, ម្តងនេះសោកនាដកម្មមែនទែន ពោលគឺរដ្ឋប្រហារពិត... តែប្រឌិតទាំងស្រុង នៃថ្ងៃទី១៨ មីនា ១៩៧០ នោះក៏ជាស្នាដៃដឹកនាំរឿងរបស់ព្រះអង្គតែមួយដូចគ្នាដែរ ។ នៅទីបំផុតទៅ សម្តេចសីហនុក៏បានលេចឡើងជា «អ្នកធ្លាក់ឆ្អែដ៏កំពូលនៃរដ្ឋប្រហារ» ដោយសារតែឋានៈរបស់ទ្រង់ជាព្រះរាជា, ដោយសារតែចំណូលចិត្តរបស់ទ្រង់ក្នុងការរុកគួនឆ្កើះឆ្អៀល ក្នុងទង្វើយុបយិត និងអំពើក្បត់, ដោយសារតែជំនឿរបស់ទ្រង់ទៅលើរឿងអកុសល (ដូចជារឿង «ស្តេចសតូចស្តើងសោយរាជ្យនៅនគរបី»), ដោយសារតែជំនោររបស់ព្រះអង្គជា ព្រះមេស្ស៊ី (អ្នកមានបុណ្យ) ដែលត្រូវការផ្តន្ទាទៅលើប្រជារាស្ត្រ ដែលបានបាត់បង់ជំនឿចំពោះទ្រង់ ។

បុគ្គលិកលក្ខណៈរបស់ស្តេចសីហនុមានអាការៈដូចជាកញ្ចក់ប្រេះស្រាំ, ទ្រង់ឆលះមើលការពិតក្នុងពិភពលោក និងការពិតពីខ្លួនឯង មិនឃើញទេ ។ បើទ្រង់មាន់រូបរាងធាត់កំពីងកំប៉ោង ទ្រង់មើលឃើញខ្លួនឯង ជា«ស្តេចសតូចស្តើង» ។ គឺជាសួនត្បូរ៉ូម៉ង់ទិក ដែលឆ្កួតវង្វេងនឹងរូបខ្លួនឯង (ជន Narcisse សម្លឹងមើលតែស្រមោលខ្លួនឯងនៅក្នុងអណ្តូងទឹក... ចំណែកជនសីហនុសម្លឹងមើលតែស្រមោលខ្លួនឯង ដែលចាំងដោយព្រះសូរិយាអស្តង្គត នៅក្នុងរឿង«សន្និប្រកាស»), ទ្រង់ស្រវឹងងប់ងល់ឈ្លក់នឹងមន្តស្នេហ៍របស់ប្រពន្ធខ្លួនឯង, ធ្វើមើលតែជាស្នេហាព្រាត់ប្រាស់ពីអតិតជាតិ ។ ម្ល៉ោះហើយព្រះអង្គក៏ច្រឡំយលសុបិន្តជាមួយនឹងការពិត និងច្រឡំបល់ទង្វើក្បត់ជាមួយឧត្តមគតិ ។ ដើម្បីតុបតែងការរត់ប្រាយចោលស្រុករបស់ព្រះអង្គ តំរង់ឆ្ពោះទៅបនយៀកកុង ឲ្យមានលក្ខណៈស្ងប់ស្ងៃងនៃសេចក្តីស្នេហាជាតិ ទ្រង់ក៏បានឆ្អែប្រឌិតឲ្យចេញរូបរាង នូវអំពើក្បត់របស់លន់នល់-សិរិមតៈ ដែលគាំទ្រដោយពួកក្រុមសេអ៊ីអា និងសហរដ្ឋអាមេរិក ។ ក៏ដូចព្រះ មេស្ស៊ី ដូច្នោះដែរ ស្តេចសីហនុត្រូវការវត្តមានរបស់ យូដាស (ជនក្បត់) ដែលអាចលើកដម្កើងវីរភាពរបស់ព្រះអង្គ ។ ដូច្នេះហើយបានជា មេធ្មប់ខ្មែរបានរៀបចំដួលរលំខ្លួនឯង ឲ្យមានលក្ខណៈអច្ឆរិយៈ ជាល្ខោនសោកនាដកម្ម ដើម្បីឲ្យពិភពលោកទាំងមូលមើលឃើញដោយភ្លឹកភ្លាំងជាក់ស្តែងថា ការរត់ចូលយៀកកុងរបស់ព្រះអង្គជាអំពើត្រឹមត្រូវ ។

តាមពិតសម្តេចសីហនុបានរត់ទៅដល់ត្រើយនាយនៃសេចក្តីសង្ឃឹមរបស់ព្រះអង្គរួចទៅហើយ (La terre promise), គឺត្រើយនាយកុម្មុយនិស្ត គោលប្រាថ្នាចុងចប់និងជាស្ថាពររបស់ទ្រង់ ។ ទ្រង់បានទៅដល់ជំរំពួកអ្នកឈ្នះរួចទៅហើយ (នេះជាសុបិន្តរបស់ទ្រង់ ដែលច្រឡំបល់ជាមួយនឹងការពិត) ហើយទ្រង់ក៏គ្មានគំរោងការវិលត្រឡប់មកក្រោយដែរ, ឆ្ពោះទៅកម្ពុជាវិញ ដែលជាជំរំរបស់អ្នកចាញ់ ។ ជាពិសេសព្រះអង្គនឹងត្រឡប់ចូលស្រុកវិញ តែនៅក្នុងលក្ខណៈណា ដែលមានការបោសសំអាតខ្ទេចខ្ទី ដែលសម្តេចព្រះមាតាត្រូវប៉ើងដោយសារសង្គ្រាមហូរឈាមដាប

ពោះដំរី ហើយនៅលើគំនរផេះនៃព្រះរាជវង្សពីដូនតា ស្ដេចក្រហមនរោត្តម-សីហនុ នឹងអាចតែងតាំងភរិយាវៀតណាមរបស់ទ្រង់នៅលើរាជបល្ល័ង្កនៃពូជស្ដេចអង្គរ ជាព្រះមហាក្សត្រិយានីនៃពួកជនកុម្មុយនិស្ដ ។

❑

❑ ❑

...ចំណែកលោកលន់-នល់វិញ, មនុស្សដែលគេចាត់ទុកថា ជាអ្នកផ្ដួងផ្ដើមរដ្ឋប្រហារ គឺជាអ្នករត់តាមក្រោយព្រឹត្តិការណ៍សុទ្ធសាធ ។ គាត់ពុំមែនជាមនុស្សខ្លាំងទេ តែជាមនុស្សរារែកអល់អែកជាទីបំផុត ។ នៅថ្ងៃទី១៧ មីនា ១៩៧០ទៅហើយ តែមួយថ្ងៃសោះមុនការទម្លាក់សម្ដេចព្រះប្រមុខរដ្ឋ លន់-នល់មិនទាន់ដឹងថាត្រូវធ្វើយ៉ាងណានៅឡើយទេ ។ លោកមានការភ្ញាក់ផ្អើលសំបើមណាស់ អំពីការរបេះក្បាច់ និងការរបេះអំណាចរបស់នាយចៅហ្វាយរបស់លោក, ហើយលោកក៏គ្មានមោទនភាពនៅក្នុងប្រការនេះដែរ ។ គឺជាសមុទ្រនយោបាយដ៏កញ្ច្រោលកញ្ច្រោកជាទីបំផុត ដែលលោកមិនអាចមើលឃើញច្រកចេញ ។ រដ្ឋាភិបាលហើយនិងប្រជាពលរដ្ឋរបស់លោក ជំរុញឲ្យលោកធ្វើសឹកសង្គ្រាមជាមួយនឹងយួនឈ្លានពាន ចំណែកនាយចៅហ្វាយរបស់លោក ជំរុញឲ្យលោកធ្វើសឹកសង្គ្រាមជាមួយនឹងប្រជាជាតិខ្លួនឯង ។ សម្ដេចសីហនុបានបញ្ជាឲ្យលោកដេញពួកយៀកកុងចេញពីដីខ្មែរ ស្រាប់តែឥឡូវនេះវិញ ទ្រង់ចោទលោកថាជាជនក្បត់... ព្រោះតែបានស្ដាប់បង្គាប់បញ្ជារបស់ព្រះអង្គ... តើគួរត្រូវធ្វើយ៉ាងណា ??

លន់-នល់ស្ថិតនៅក្នុងស្ថានភាពរបស់តាជ័យ ឬតាត្រសក់ផ្អែម ដែលជាដើមរាជវង្សនៃក្រុងអង្គររបស់ស្ដេចសីហនុ ។ មហាក្សត្រចុងក្រោយនៃទីក្រុងអង្គរដែលជាពូជពង្សវរ្ម័ន ស្រាប់តែធ្លាក់ខ្លួនឆ្កួតមួយរំពេជ ។ ទ្រង់ក៏មានឈ្មោះថាសីហនុដែរ (ព្រះសីហនុរាជ ឬស្ដេចពាល) ។ ស្ដេចអង្គរបានបង្គាប់បញ្ជាឲ្យតាជ័យ (ពាក្យខ្លះថា តាឆាយ ៖ ជ័យា ហើយនិងឆាយាមានន័យដូចគ្នា គឺរស្មីព្រះអាទិត្យ) អ្នកយាមចំការត្រសក់ ឲ្យពិឃាតដោយលំពែង ជនណាក៏ដោយ ដែលហ៊ានដើរចូលចំការត្រសក់ (ផ្អែម) របស់ព្រះអង្គ ។ តាមពិតគឺស្ដេចអង្គឯង ដែលក្នុងឱកាសនៃរាត្រីមួយដ៏សែនងងឹត បានចុះទៅក្នុងចំការត្រសក់ជាមួយនឹងស្រីពីររូប ហើយក៏ត្រូវធ្លុះខ្លួនពីម្ខាងទៅម្ខាង ដោយសារលំពែងរបស់តាជ័យ ។ ប្រជាជននៃក្រុងអង្គរក៏តែងតាំងតាជ័យ ជាព្រះមហាក្សត្រជំនួសស្ដេចដែលទើបសុគតទៅ ។ ចំណែកសម្ដេចសីហនុនៃសតវត្សទី២០វិញ ក៏ដូចគ្នាដែរ បានបង្គាប់បញ្ជាឲ្យលន់-នល់ ពន្លិចទូកពួកយៀកកុង ។ ក៏ប៉ុន្តែនៅពេលដែលលន់-នល់កំពុងតែបំពេញបេសកកម្មដេញយួនឈ្លានពាន ដោយជឿទាំងស្រុងទៅលើមនោសញ្ចេតនាស្នេហាជាតិរបស់នាយចៅហ្វាយ ក៏ស្រាប់តែព្រះអគ្គមគ្គទ្វេសក៏ដ៏ឆ្នើម នរោត្តម-សីហនុ លោតផ្លោតចូលទៅក្នុងទូកយួនបណ្ដោយទៅ ។ នៅពេលនោះ គឺវាហួសពេលទៅហើយសំរាប់នល់-នល់ ដើម្បីស្ដារស្ថានភាពនគរក្រុងកម្ពុជាឡើងវិញ ។៚